# គោរពស្នើសុំយោបល់

**យោង** : សំណើសុំរបស់ម៉ៅ វណ្ណកាង

**កម្មវត្ថុ** : សំណើសុំចុះឈ្មោះអ្នកទទួលសិទ្ធិ ក្នុងឯកសារស្នើសុំចុះបញ្ជីបំពេញបន្ថែម និងសុំកាត់បន្ថយរយៈពេល

**សេចក្ដីសង្ខេបរឿង** :

១-ដីមួយកន្លែងស្ថិតនៅផ្លូវសឡា ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ មាន**វិវាទតាំងពីឆ្នាំ** ១៩៩៨ និងបានបញ្ចប់ជាស្ថាពរនៅឆ្នាំ២០០២ តាមអំណាចសាលដីកាតុលាការកំពូលលេខ ១៩២ ចុះថ្ងៃទី ១៥-០៨-០២ និង មានកំណត់ហេតុអនុវត្តសាលដីកាចុះថ្ងៃទី ០៨-១០-០៥ ដោយប្រគល់ដីទំហំ ៦៤៨០០ ម² (ប្រាំមួយម៉ឺន បួនពាន់ប្រាំបីរយ ម៉ែត្រការ៉េ ) ឱ្យឈ្មោះ តា វរៈសត្ថា និង តា រដ្ឋាភិរម្យ ( តំណាងអោយក្រុមហ៊ុនបេតាអន្តរជាតិ ) ហើយឯកភាពយកតាមគំនូសប្លង់របស់ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃ ២៣-០៥-០៣ ។

២-នៅថ្ងៃ២០-០៣-០៤ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ត្រូវបានកំណត់ជាតំបន់វិនិច្ឆ័យសំរាប់ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ។ ដំណើរការអនុវត្តបានប្រព្រឹត្តទៅរហូតដល់ថ្ងៃ ២០-០៣-០៦ ទើបបិទផ្សាយទិន្នន័យ ហើយចាប់ពីថ្ងៃ ១៥-០៦-០៦ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុត្រូវបានប្រកាសចែកជូនប្រជាពលរដ្ឋជាម្ចាស់ ។ ប៉ុន្តែដីដែលមានវិវាទខាងលើត្រូវបានក្រុមការងារ**វៀលចោល** ។

៣-នៅថ្ងៃ១៦-១២-០៥ មួយចំណែកនៃដីដែលបានអនុវត្តសាលដីការួចហើយ ( ទំហំ១៩២៨៣ ម² ) **ត្រូវបានកាត់**លក់ឱ្យឈ្មោះម៉ៅ វណ្ណកាង ហើយបានចុះបញ្ជីដីតាមនីតិវិធីមានលក្ខណៈដាច់ដោយដុំ កាលពីថ្ងៃ ២៣-១២-០៥ ។ មានភ្ជាប់ប្លង់បំបែកក្បាលដីដែលបានកំណត់ព្រំ និងវាស់វែងដោយមន្ត្រីការិយាល័យសុរិយោដី និងភូមិសាស្ត្រ ចុះថ្ងៃ១៤-១១-០៥ ។

**សំណូមពររបស់ម្ចាស់ដី (ម៉ៅ វណ្ណកាង ) :**

-សុំចុះបញ្ជីបំពេញបន្ថែមនូវក្បាលដីដែលខ្លួនបានទិញ ពីម្ចាស់ដែលទទួលបានពីការអនុវត្តសាលដីកា ដោយដាក់**ឈ្មោះអ្នកទិញតែម្ដងក្នុងសំណុំរឿងចុះបញ្ជីដី**បំពេញបន្ថែម ( ទំរង់បែបបទ សៀវភៅគោលបញ្ជីដី និងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ) ។

-សុំកាត់ចោល**រយៈពេលនៃការបិទផ្សាយទិន្នន័យនៃការវិនិច្ឆ័យ** និងរយៈពេលជូនដំណឹងពាក់ព័ន្ធ ព្រោះក្បាលដីនេះត្រូវបានបញ្ចប់វិវាទរួចហើយ ហើយព្រំនៃក្បាលដីត្រូវបានកំណត់ដោយគណៈកម្មការរដ្ឋបាលពេលអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ឯព្រំពុះបំបែកក្បាលដីក៏ត្រូវបានកំណត់រួចហើយដែរ នៅពេលធ្វើសាលាកប័ត្របំបែកលក់ ។

**មតិរបស់នាយកដ្ឋានអតិរេក្ស :**

- ករណីនេះ អាចចុះបញ្ជីឈ្មោះអ្នកទិញតែម្ដងក្នុងសំណុំឯកសារចុះបញ្ជីបំពេញបន្ថែម ( យោងមតិរបស់អគ្គនាយកចុះថ្ងៃ ០៩-០១-០៧ លើករណីដីរបស់ប្រាក់ សុខុន នៅក្រុងព្រះសីហនុ ) តែត្រូវបង់ពន្ធប្រថាប់ត្រាជាចាំបាច់ ។

- អាចកាត់ចោលរយៈពេលជូនដំណឹង និងរយៈពេលបិទផ្សាយទិន្នន័យបាន ព្រោះវិវាទត្រូវបានដោះស្រាយចប់សព្វគ្រប់ហើយ ឯព្រំក្បាលដីត្រូវបានកំណត់ជាផ្លូវការតាមរយៈការអនុវត្តសាលដីកា និងមានការចូលរួមពីអ្នកពាក់ព័ន្ធរួចហើយ ( ព្រំត្រង់កន្លែងបំបែកក្បាលដី ) នៅពេលកំណត់ព្រំ និងវាស់បំបែកក្បាលដី ។

ភ្នំពេញ .ថ្ងៃ ២៩ ខែ មករា ឆ្នាំ ២០០៧

ប្រធាន ,

ឯកភាព

26/01